ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

លេខ : ០៣៨ បទ.ប្រក

ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ២០០៤

# ប្រកាស

## ស្តីពី

## ឆ្នាក់ទារប្រៃសណីយ៍

## រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការបង្កើតក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០២/០១២ ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ២០០២ ដែលប្រកាសអោយប្រើច្បាប់ស្តីពីវិស័យប្រៃសណីយ៍ ។
- បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ/បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ។
- បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ/បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ២០០២ ស្តីពីការកែសំរួល និង បំពេញបន្ថែមនាយកដ្ឋានមួយចំនួននៃក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ។
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ/បក ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ២០០៣ ស្តីពីការតម្លើងនាយកដ្ឋានរដ្ឋបាល និងបណ្តុះបណ្តាល ទៅជាអគ្គនាយកដ្ឋានរដ្ឋបាល នៃក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ។
- យោងតាមសំណើររបស់នាយកដ្ឋាននយោបាយប្រៃសណីយ៍និយ័តនិងទំនាក់ទំនងអន្តរជាតិ ។
- តាមសេចក្តីសំរេចរបស់អង្គប្រជុំថ្នាក់ដឹកនាំក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ថ្ងៃទី ២៧ ខែ មករា ឆ្នាំ២០០៤ ។

# សំ រេ ច

**ប្រការ ១ :**

អនុញ្ញាតអោយរូបវន្តបុគ្គល ធ្វើជាភ្នាក់ងារប្រៃសណីយ៍សំរាប់ទទួលលក់ តែមប្រៃសណីយ៍ តែមប្រើវិទ្យា លិខិតអេរ៉ូប្រ៉ាម ប្រៃសណីយ៍ប័ត្រមានតម្លៃស្រាប់ អាល់ប៊ុមតែមប្រើ និងបំរើសេវា ទទួលផ្ញើ សំបុត្រ លិខិតអេរ៉ូប្រ៉ាម ប្រៃសណីយ៍ប័ត្រមានតម្លៃស្រាប់ កលិកបត្រ័ និង កញ្ចប់តូច មានទំងន់អតិបរិមា ៥០០ក្រាម ។

**ប្រការ ២ :-**

កំណត់លក្ខណៈសម្បត្តិរូបវន្តបុគ្គលធ្វើជាភ្នាក់ងារប្រៃសណីយ៍ដូចខាងក្រោម :

- មានសញ្ជាតិខ្មែរ
- មានកាយសម្បទារគ្រប់គ្រាន់
- មានសញ្ញាប័ត្រប្រៃសណីយ៍ ឬ វិញ្ញាបនប័ត្រ ឬ ធ្លាប់បានទទួលការណែនាំដកស្រង់បទពិសោធន៍ពីសមត្ថកិច្ចប្រៃសណីយ៍ ឬ មានបទពិសោធន៍លើការងារប្រៃសណីយ៍ ដែលទទួលស្គាល់ដោយស្ថាប័នប្រៃសណីយ៍នៃប្រទេសណាមួយ។
- មានទីតាំងសមស្រប និង ច្បាស់លាស់
- ទីតាំងរបស់ភ្នាក់ងារប្រៃសណីយ៍នីមួយៗ ត្រូវស្ថិតនៅអោយឆ្ងាយពីគ្នា ព្រមទាំងឆ្ងាយពីការិយាល័យប្រៃសណីយ៍យ៉ាងតិច៥០០ម ។
- មិនដែលមានទោសពីបទល្មើសព្រហ្មទណ្ឌណាមួយ ។

**ប្រការ ៣ :-**

កំណត់ថ្លៃលិខិតអនុញ្ញាតធ្វើជាភ្នាក់ងារប្រៃសណីយ៍ ចំនួន ៥០.០០០រៀល និងប្រាក់ធានាសេវាសំរាប់ទទួលផ្ញើសំបុត្រ លិខិតអេរ៉ូប្រ៉ាម ប្រៃសណីយ៍ប័ត្រមានតម្លៃស្រាប់ កលិកបត្រ័ និងកញ្ចប់តូចចំនួន ៤០០.០០០រៀល។ ភ្នាក់ងារប្រៃសណីយ៍នីមួយៗ អាចដកយកប្រាក់ធានាវិញបាននៅពេលណាភ្នាក់ងារនោះ បានសុំលាឈប់ដោយមានការយល់ព្រម ពីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍។

**ប្រការ ៤ :-**

លិខិតអនុញ្ញាតអោយធ្វើជាភ្នាក់ងារប្រៃសណីយ៍ មានសុពលភាពរយៈពេល១ឆ្នាំ គិតចាប់ពីថ្ងៃចុះហត្ថលេខា ហើយអាចសុំបន្តមួយឆ្នាំម្តងៗ។ ការសុំច្បាប់បន្តធ្វើជាភ្នាក់ងារប្រៃសណីយ៍ត្រូវដាក់ពាក្យសុំអោយបាន៣០ថ្ងៃមុនពេលលិខិតអនុញ្ញាតអស់សុពលភាព។

ប្រការ ៥ :-

ភ្នាក់ងារប្រៃសណីយ៍នីមួយៗ មិនអាច ជួល លក់ ឬ បញ្ចាំ លិខិតអនុញ្ញាតធ្វើជាភ្នាក់ងាររបស់ខ្លួនទៅអោយអ្នកផ្សេងបានឡើយ ។

ប្រការ ៦ :-

ភ្នាក់ងារប្រៃសណីយ៍ទាំងអស់ ត្រូវបានទទួលប្រាក់អប្បហារ ឬកម្រៃចំនួន៥% (ប្រាំភាគរយ) ពីការលក់តែមប្រៃសណីយ៍ តែមប្រឹទ្យា លិខិតអេរ៉ូក្រាម ប្រៃសណីយ៍ប័ត្រមានតម្លៃស្រាប់ និង អាល់ប៊ុមតែមប្រ៊ី ។

ប្រការ ៧ :-

ភ្នាក់ងារប្រៃសណីយ៍នីមួយៗ ត្រូវបានទទួលនូវត្រាថ្ងៃ-ខែ ដែលកំណត់ទីតាំងតាមកូដប្រៃសណីយ៍ និង លេខរៀងបញ្ជី ព្រមទាំងសំភារៈសំរាប់ទទួលផ្ញើ សំបុត្រ លិខិតអេរ៉ូក្រាម ប្រៃសណីយ៍ប័ត្រមានតម្លៃស្រាប់ កលិកបត្រ័ និងកញ្ចប់តូច ពីនាយកដ្ឋានប្រៃសណីយ៍ ។

ប្រការ ៨ :-

រាល់សំបុត្រ លិខិតអេរ៉ូក្រាម ប្រៃសណីយ៍ប័ត្រមានតម្លៃស្រាប់ កលិកបត្រ័ និង កញ្ចប់តូច ដែលភ្នាក់ងារប្រៃសណីយ៍ទទួលបានពីអតិថិជន ត្រូវបញ្ជូនទៅការិយាល័យប្រៃសណីយ៍ដែលនៅជិតទីតាំងរបស់ខ្លួន ដើម្បីអោយការិយាល័យប្រៃសណីយ៍នោះ តាមដានត្រួតពិនិត្យលក្ខណៈសម្បត្តិនៃបញ្ញើ ឬពាក្យបណ្តឹងតវ៉ាផ្សេងៗពីអតិថិជន មុននឹងបញ្ជូនបញ្ញើចេញ ។

ប្រការ ៩ :-

ភ្នាក់ងារប្រៃសណីយ៍ទាំងអស់ ត្រូវគោរពល័ក្ខខ័ណ្ឌទាំងឡាយ ស្តីពីភ្នាក់ងារប្រៃសណីយ៍ កិច្ចសន្យា និង លិខិតបទដ្ឋាននានារបស់ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ព្រមទាំងច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា។ ក្នុងករណីប្រព្រឹត្តខុសនិងល័ក្ខខ័ណ្ឌនេះ ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ មានសិទ្ធិកែ សំរួល ព្យួរ ដកហូត ឬ បដិសេធលិខិតអនុញ្ញាតធ្វើជាភ្នាក់ងារប្រៃសណីយ៍ ទៅតាមរូបភាពដូចខាងក្រោម :

ក/ ការកែសំរួល និងព្យួរលិខិតអនុញ្ញាតធ្វើជាភ្នាក់ងារប្រៃសណីយ៍ :

- ការអនុវត្តន៏ខុសពីការកំណត់ក្នុងលិខិតអនុញ្ញាតធ្វើជាភ្នាក់ងារប្រៃសណីយ៍
- គ្មានសកម្មភាពរយៈពេល៣ខែបន្ទាប់ពីទទួលបានលិខិតអនុញ្ញាតធ្វើជាភ្នាក់ងារប្រៃសណីយ៍ ។
- ពុំបានអនុវត្តន៏ត្រឹមត្រូវតាមសារាចរណែនាំ របស់ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

លិខិតអនុញ្ញាតធ្វើជាភ្នាក់ងារប្រៃសណីយ៍ដែលបានកែសំរួល ព្យួរ មានរយៈពេលរហូតដល់អស់សុពលភាព ប្រសិនបើភ្នាក់ងារប្រៃសណីយ៍នោះ ពុំបានមកបំពេញកិច្ចសន្យាឈប់ប្រព្រឹត្តខុសនឹងល័ក្ខខ័ណ្ឌក្នុងរយៈពេលមិនលើសពី ១៥ថ្ងៃ ។

ខ/ ការដកហូត ឬការបដិសេធលិខិតអនុញ្ញាតធ្វើជាភ្នាក់ងារប្រៃសណីយ៍

- ក្នុងករណីមានការកែសំរួល ឬ ព្យួរ លិខិតអនុញ្ញាតធ្វើជាភ្នាក់ងារប្រៃសណីយ៍ចំនួនពីរដង ហើយពុំព្រមរាងចាល ។
- លិខិតអនុញ្ញាតធ្វើជាភ្នាក់ងារប្រៃសណីយ៍អស់សុពលភាពហើយពុំបានស្នើសុំបន្ត
- ករណី ផ្ទុយនឹងប្រការ៥។

## ប្រការ ១០ :-

រាល់ប្រកាសទាំងឡាយណាដែលផ្ទុយពីខ្លឹមសារនៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

## ប្រការ ១១ :-

អគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានប្រៃសណីយ៍ និង ទូរគមនាគមន៍ ខុទ្ទកាល័យ អធិការដ្ឋាន គ្រប់នាយកដ្ឋានក្រោមឱវាទក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ និងគ្រប់មន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្ត-ក្រុង ត្រូវទទួលបន្ទុកអនុវត្តតាមខ្លឹមសារនៃប្រកាសនេះ។

## ប្រការ ១២ :-

ប្រកាសនេះមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

សូ-ឃុន

កន្លែងទទួល

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ១១ "ដើម្បីអនុវត្តន៍"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ